ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

# សមាជិកសភានៃតំបន់អាស៊ីអាគ្នេយ៍ ថ្លែងថា សភានៃប្រទេសម៉ាឡេស៊ី ត្រូវតែត្រូវបានអនុញ្ញាតឲ្យបើកកិច្ចប្រជុំ ក្នុងអំឡុងពេលនៃភាពអាសន្ន

ថ្ងៃនេះ សមាជិកសភាជាង ៨០ នាក់ នៅទូទាំងតំបន់ បានសម្តែងនូវការព្រួយបារម្ភជុំវិញសិទ្ធិអំណាចយ៉ាងធំទូលំទូលាយហួសប្រមាណ ដែលត្រូវបានប្រគល់ឲ្យអាជ្ញាធរម៉ាឡេស៊ី ស្ថិតក្រោមភាពអាសន្ននាពេលបច្ចុប្បន្ន និងជម្រុញឲ្យព្រះមហាក្សត្រ ប្រធានសភាតំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីម៉ាឡេស៊ី ធ្វើការកោះប្រជុំសភាក្នុងពេលវេលាកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។

នៅក្នុងសេចក្ដីថ្លែងការណ៍ដែលមានរាយនាមសមាជិកសភាក្នុងតំបន់ដែលគាំទ្រសេចក្ដីថ្លែងការណ៍នេះ អតីតសមាជិកសភា និងសមាជិកសភាជាប់ឆ្នោតតាមបែបបទប្រជាធិបតេយ្យបច្ចុប្បន្ន ចំនួន ៨៩នាក់ មកពីប្រាំមួយប្រទេស ក៏បានអំពាវនាវផងដែរដល់ប្រធានសភាតំណាងរាស្ត្រឲ្យធានាថា គណៈកម្មការជំនាញនានានៃសភានៅតែមានដំណើរការយ៉ាងសកម្ម និងបើកកិច្ចប្រជុំជាទៀងទាត់។

លោក Tom Villarin សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស (APHR) និងជាអតីតសមាជិកសភាហ្វីលីពីន មានប្រសាសន៍ថា “ការណ៍ដែលសមាជិកសភាជាច្រើនរូបនៅទូទាំងតំបន់កំពុងធ្វើការតស៊ូមតិលើបញ្ហានេះ បង្ហាញឲ្យឃើញពីក្ដីព្រួយបារម្ភនៅកម្រិតតំបន់ជុំវិញផលប៉ះពាល់នៃភាពអាសន្នលើប្រជាធិបតេយ្យសភានៅក្នុងប្រទេសម៉ាឡេស៊ី និងផលប៉ះពាល់យូរអង្វែងដែលអាចកើតមាននាពេលអនាគត ទៅលើអាយុជីវិតនៃប្រជាពលរដ្ឋម៉ាឡេស៊ី។ យើងបានឃើញហើយថាតើវិធានការពាក់ព័ន្ធនឹងការរីករាលដាលនៃជំងឺឆ្លងនេះ ដែលត្រូវបានអនុម័តនៅក្នុងបណ្ដាប្រទេសផ្សេងៗទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ កាន់តែរឹតត្បិតសិទ្ធិមនុស្សយ៉ាងដូចម្ដេចខ្លះ? ហើយថាតើការការពារសុវត្ថិភាពដោយត្រឹមត្រូវត្រូវតែអនុវត្តយ៉ាងដូចម្ដេច?”

លោក Villarin ថ្លែងថា “ខណៈពេលដែលរដ្ឋាភិបាលផ្ដល់អាទិភាពលើការដោះស្រាយបញ្ហាជំងឺ COVID-19 វាពិតជាមានសារៈសំខាន់ណាស់ដែលថា វិធានការឆ្លើយតបនឹងជំងឺនេះត្រូវប្រកាន់ខ្ជាប់នូវដំណោះស្រាយដែលយកសិទ្ធិមនុស្សជាមូលដ្ឋាន និងគោរពនីតិរដ្ឋ។ ផ្ទុយទៅវិញ ស្ថានភាពនៃគ្រាអាសន្នរបស់ប្រទេសម៉ាឡេស៊ី មិនត្រឹមតែបានប្រមូលផ្ដុំសិទ្ធិអំណាចយ៉ាងធំទូលំទូលាយហួសប្រមាណនៅក្នុងអង្គនីតិប្រតិបត្តិ ប៉ុន្តែថែមទាំងបានដកចេញនូវយន្តការត្រួតពិនិត្យជាក់ស្ដែងផងដែរ ដោយបើកឱកាសយ៉ាងធំទូលាយឲ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។”

នៅខណៈពេលដែលមានការកើនឡើងនូវករណីជំងឺ COVID-19 កាលពីខែមករាកន្លងទៅ ព្រះមហាក្សត្រម៉ាឡេស៊ី បានប្រកាសភាពអាសន្ននៅទូទាំងប្រទេស ចាប់ពីថ្ងៃទី១១ ខែមករា រហូតដល់ថ្ងៃទី០១ ខែសីហា។ ដោយឡែក សមាជិកសភាបានសង្កត់ធ្ងន់ទៅលើសិទ្ធិអំណាចដែលគ្មានការត្រួតពិនិត្យ និងដែលមានផលប៉ះពាល់យ៉ាងទូលំទូលាយ ក្រោមបទបញ្ជាភាពអាសន្ន (អំណាចចាំបាច់) ឆ្នាំ២០២១ ដែលរួមបញ្ចូលទាំងសិទ្ធិអំណាចបន្ថែមសម្រាប់កងកម្លាំងប្រដាប់អាវុធ ការព្យួរសភា និងកិច្ចប្រជុំរដ្ឋសភា ជាបណ្ដោះអាសន្ន ការលើកពេលការបោះឆ្នោត និងអភ័យឯកសិទ្ធិច្បាប់សម្រាប់ទង្វើរបស់អាជ្ញាធរ ដែលត្រូវបានប្រព្រឹត្តដោយ "សេចក្ដីស្មោះត្រង់"។

ក្រុមសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស (APHR) ថ្លែងថា វិធានការទាំងនេះជាការរំលោភបំពានលើបទដ្ឋានអន្តរជាតិ ព្រមទាំងបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវដំណើរការប្រជាធិបតេយ្យ និងបង្កឲ្យមានបរិយាកាសអំណោយផលល្អសម្រាប់ការរំលោភអំណាច។ ក្រោមច្បាប់អន្តរជាតិ វិធានការបន្ទាន់ក្នុងភាពអាសន្នត្រូវតែមានលក្ខណៈចាំបាច់ និងសមស្រប ក្នុងការសម្រេចឲ្យបាននូវលទ្ធផលដែលចង់បាន ព្រមទាំងមានលក្ខណៈបណ្ដោះអាសន្ន ត្រូវបានអនុវត្តដោយគ្មានការរើសអើង និងអាចត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញ។

*លោក Villarin មានប្រសាសន៍ថា "រដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី Muhyiddin ដែលមិនកើតចេញពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ បានស្ថិតនៅក្នុងស្ថានភាពគ្មានលំនឹង ចាប់តាំងពីការចូលកាន់អំណាច កាលពីឆ្នាំមុនមកម្ល៉េះ ហើយវិធានការចុងក្រោយនេះគឺទំនងជាការប៉ុនប៉ងក្នុងការក្ដោបក្ដាប់អំណាចបន្តទៀត ជាជាងការដោះស្រាយវិបត្តិសុខភាពប្រកបដោយប្រសិទ្ធភាព។"*

*លោក Villarin មានប្រសាសន៍បន្ថែមទៀតថា "នេះមិនមែនជាពេលវេលាក្នុងការបំបិទសំឡេងរបស់សមាជិកសភានោះទេ។ ក្នុងកាលៈទេសៈនៃវិបត្តិសុខភាព វារឹតតែមានសារៈសំខាន់ខ្លាំងណាស់ដែលថា សភាអាចធ្វើមុខការយ៉ាងមានប្រសិទ្ធភាព ក្នុងការត្រួតពិនិត្យសកម្មភាព និងគោលនយោបាយរបស់រដ្ឋាភិបាល រួមទាំងវិធានការឆ្លើយតបនឹងការរីករាលដាលនៃជំងឺឆ្លងនេះ។ អ្វីដែលពិភពលោកត្រូវការនាពេលនេះគឺ តម្លាភាព និងគណនេយ្យភាពជាងមុន មិនមែនការបិទបាំងការពាររបស់រដ្ឋាភិបាលពីការត្រួតពិនិត្យសាធារណៈនោះទេ។"*

កន្លងមក សភាម៉ាឡេស៊ីធ្លាប់ប្រឈមនឹងការរឹតត្បិតដោយសារតែការរីករាលដាលនៃជំងឺឆ្លងនេះ។ កាលពីខែវិច្ឆិកា ឆ្នាំ២០២០កន្លងទៅ សភាតំណាងរាស្ត្របានអនុម័តវិធានការទប់ស្កាត់ជំងឺ COVID-19 ដែលរួមមានទាំងការកាត់បង្រួមដំណើរការនីតិវិធី និងចំនួនម៉ោងនៃកិច្ចប្រជុំ និងការកំណត់ចំនួនសមាជិកសភា ៨០រូបជាអតិបរមា នៅក្នុងកិច្ចប្រជុំពេញអង្គនីមួយៗ។

កិច្ចប្រជុំសភានៅខែមីនា-មេសា ឆ្នាំ២០២០ ក៏ត្រូវបានលើកពេល និងប្តូរទៅជាកិច្ចប្រជុំរយៈពេលមួយថ្ងៃ នៅខែឧសភាវិញ ដោយគ្មានការពិភាក្សាដេញដោល។

ចាប់តាំងពីពេលនោះមក មានការដាក់ពាក្យបណ្តឹងជាច្រើនពាក់ព័ន្ធនឹងភាពអាសន្ននេះ រួមមានទាំងបណ្តឹងផលប្រយោជន៍សាធារណៈមួយ ក្នុងចំណោមបណ្តឹងដទៃផ្សេងទៀត ដែលត្រូវបានប្តឹងដោយអង្គការសង្គមស៊ីវិល ឲ្យធ្វើការត្រួតពិនិត្យឡើងវិញនូវការព្យួរសភា។

សារតារ

កាលពីឆ្នាំមុន ប្រទេសម៉ាឡេស៊ីបានប្រឈមនឹងចលាចលនយោបាយ ហើយកាលពីខែមីនា ឆ្នាំ២០២០កន្លងទៅ លោកនាយករដ្ឋមន្ត្រី Muhyiddin Yassin បានលេចមុខឡើងជាមេដឹកនាំសម្ព័ន្ធភាពមួយជាមួយសំឡេងភាគច្រើននៃសមាជិកសភាតែពីរបីនាក់ប៉ុណ្ណោះ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី Mahathir Mohamed បានលាលែងពីដំណែង។ ស្ថានភាពនេះបាននាំឲ្យមានការអំពាវនាវឲ្យមានការបោះឆ្នោតសម្តែងការមិនទុកចិត្តប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី Muhyiddin ព្រមទាំងមានការប្រមើលថាអាចនឹងកើតមានការបោះឆ្នោតមុនកាលកំណត់។ កាលពីដើមឆ្នាំនេះ សមាជិកសភាជាច្រើនរូបបានដកការគាំទ្ររបស់ពួកគេចំពោះលោកនាយករដ្ឋមន្ត្រីមកវិញ ដែលការណ៍នេះត្រូវបានគេរាយការណ៍ថា បានគម្រាមកំហែងដល់សំឡេងភាគច្រើនស្តួចស្តើងរបស់លោកនាយករដ្ឋមន្ត្រីនៅក្នុងសភា។